**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

លេខ ០៣៤ អបស/កស

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារបច្ចេកទេស ប្រឡងប្រណាំងពាក់ព័ន្ធការឆ្លើយតប ទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញគោលនយោបាយរបស់រាជរដ្ឋាភិបាលលេខ ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"
- បានឃើញលិខិតលេខ ១០៧ សជណ.មយ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ របស់ទីស្តីការគណៈរដ្ឋមន្ត្រីស្តីពីករណីសំណើសុំគោលការណ៍ដឹកនាំអំពីការអនុវត្តចលនាប្រឡងប្រណាំងគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"
- បានឃើញលិខិតលេខ ០២៨ អបស/ក.ស ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងសុខាភិបាលស្តីពីបង្កើតគណៈកម្មការ ប្រឡងប្រណាំងពាក់ព័ន្ធការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេស ប្រឡងប្រណាំងពាក់ព័ន្ធការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧ នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមវេជ្ជបណ្ឌិត | **សាន់ សាប់អី** | រដ្ឋលេខាធិការ ក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តមវេជ្ជបណ្ឌិត | **ហុក គីមចេង** | អគ្គនាយកបច្ចេកទេសសុខាភិបាល | អនុប្រធាន |
| ៣-ឯកឧត្តម | **ឃុន សុខា** | ទីប្រឹក្សា គ.ជ.គ.ម. និងជាប្រធាននាយកដ្ឋានអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាល | អនុប្រធាន |
| ៤-ឯកឧត្តមវេជ្ជបណ្ឌិត | **លី សុវ៉ាន់** | ប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | អនុប្រធាន |

| | | | |
|---|---|---|---|
| ៥-លោកវេជ្ជបណ្ឌិត | **កុល ហៀវ** | ប្រធាននាយកដ្ឋានការពារសុខភាព | អនុប្រធានអចិន្ត្រៃយ៍ |
| ៦-លោកវេជ្ជបណ្ឌិត | **ឈិត សុផល** | ប្រធាននាយកដ្ឋានសុខភាពផ្លូវចិត្ត និងការបំពានគ្រឿងញៀន | សមាជិក |
| ៧-លោកស្រីវេជ្ជបណ្ឌិត | **ឆូច សុខនាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស | សមាជិក |
| ៨-ឯកឧត្តមសាស្ត្រាចារ្យ | **ទី ម៉េង** | នាយកមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ៩-ឯកឧត្តមសាស្ត្រាចារ្យរង | **លូ លីឃាង** | នាយកមន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ១០-លោកវេជ្ជបណ្ឌិត | **លី វិជ្ជារ៉ាវុធ** | ប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | សមាជិក |
| ១១-លោកស្រីវេជ្ជបណ្ឌិត | **គីម រ័ត្ននា** | នាយកមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក | សមាជិក |
| ១២-លោកសាស្ត្រាចារ្យ | **ញ៉ឹប អង្គារបុស្ស** | នាយកមន្ទីរពេទ្យកុមារជាតិ | សមាជិក |
| ១៣-លោក | **ហេង គង់ម៉េង** | អនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ១៤-លោកឧត្តមសេនីយ៍ឯក | **ម៉ឹង បូរ៉ា** | អនុប្រធាននាយកដ្ឋាននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៥-លោកឧត្តមសេនីយ៍ទោ | **ខិ សំណាង** | អនុប្រធាននាយកដ្ឋាននៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ | សមាជិក |
| ១៦-លោកវេជ្ជបណ្ឌិត | **ឡាក់ ឡេង** | នាយករងមជ្ឈមណ្ឌលជាតិលើកកម្ពស់សុខភាព | សមាជិក |
| ១៧-លោកវេជ្ជបណ្ឌិត | **ឃី សេងធឿន** | អនុប្រធាននាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លង | សមាជិក |
| ១៨-លោកស្រីវេជ្ជបណ្ឌិត | **ជន ស៊ីនួន** | អនុប្រធាននាយកដ្ឋានមន្ទីរពេទ្យ | សមាជិក |
| ១៩-លោកស្រីវេជ្ជបណ្ឌិត | **លន់ មណ្ឌល** | អនុប្រធាននាយកដ្ឋានផែនការ និងព័ត៌មានសុខាភិបាល | សមាជិក |
| ២០-លោកទន្តបណ្ឌិត | **ចាន់ វិចិត្រ** | នាយករងមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ២១-លោកសាស្ត្រាចារ្យ | **គីម អាង** | នាយករងមន្ទីរពេទ្យកុមារជាតិ | សមាជិក |
| ២២-លោកវេជ្ជបណ្ឌិត | **ជុំ ម៉េងឡុង** | នាយករងមន្ទីរពេទ្យព្រះអង្គឌួង | សមាជិក |
| ២៣-លោក | **ខ្វាន់ ចន្ទឧត្តម** | ប្រធានការិយាល័យនៃអគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ | សមាជិក |
| ២៤-លោកស្រីវេជ្ជបណ្ឌិត | **លាង សុភាព** | ប្រធានការិយាល័យបច្ចេកទេស វិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក |
| ២៥-លោកស្រីវេជ្ជបណ្ឌិត | **ឡាក់ មួយស៊ាង** | អនុប្រធាននាយកដ្ឋានការពារសុខភាព | ប្រធានលេខាធិការ |
| ២៦-លោកគ្រូពេទ្យ | **អៀង សុខគី** | ប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន | លេខាធិការអចិន្ត្រៃយ៍ |
| ២៧-លោក | **ជិន អាត** | អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន | អនុប្រធានលេខាធិការ |
| ២៨-កញ្ញាវេជ្ជបណ្ឌិត | **ថុល ដាវីន** | អនុប្រធានការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយនិងសុខភាពបរិស្ថាន | សមាជិក |
| ២៩-លោក | **តុង រដ្ឋា** | មន្ត្រីការិយាល័យគ្រប់គ្រងគ្រោះមហន្តរាយ និងសុខភាពបរិស្ថាន | សមាជិក |

| | |
|---|---|
| ៣០-មន្ត្រីបច្ចេកទេសតំណាងអង្គការសុខភាពពិភពលោក (WHO) | សមាជិក |
| ៣១-មន្ត្រីបច្ចេកទេសតំណាងអង្គការ UNICEF | សមាជិក |
| ៣២-មន្ត្រីបច្ចេកទេសតំណាងអង្គការ GIZ | សមាជិក |

**ប្រការ២.-**

ក្រុមការងារបច្ចេកទេសមានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំបទដ្ឋានគតិយុត្តិ បទប្បញ្ញត្តិ និងលក្ខខណ្ឌនានា ពាក់ព័ន្ធទៅនឹងការប្រឡងប្រណាំងក្នុងការឆ្លើយតបទាន់ពេលវេលាចំពោះគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវ ដែលជាលក្ខណៈសម្បត្តិទី៧នៃគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"
- រៀបចំផែនការសកម្មភាពនានា ទាក់ទងទៅនឹងការវាយតម្លៃការងារប្រឡងប្រណាំងការឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា
- រៀបចំតាក់តែងឧបករណ៍ និងសូចនាករសម្រាប់អនុវត្តលើចលនាប្រឡងប្រណាំងដល់ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" រាជធានី-ខេត្ត ស្តីពី ការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាលមកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា នៅក្នុងមូលដ្ឋានដូចជា ជំងឺកូវីដ-១៩... សំដៅស្វែងរក "ភូមិ ឃុំ-សង្កាត់ ដែលបានខិតខំព្យាយាមពុះពារបំពេញភារកិច្ច បង្កើតបានជាស្នាដៃធំធេងធ្វើជាគំរូក្នុងការអនុវត្តគោលនយោបាយដែលមានលក្ខណៈសម្បត្តិទទី៧ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព"
- រៀបចំកម្មវិធីបណ្តុះបណ្តាល និងធ្វើលំហាត់សមយុទ្ធអំពីការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលាពីការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានា ដល់មន្ត្រីមូលដ្ឋាន ភូមិ ឃុំ សង្កាត់ ពាក់ព័ន្ធទៅនឹងការប្រឡងប្រណាំង
- តាមដាន និងវាយតម្លៃប្រចាំឆ្នាំលើចលនាប្រឡងប្រណាំងក្នុងការអនុវត្តបានល្អនូវឧបករណ៍ និងសូចនាករពាក់ព័ន្ធការត្រៀម និងឆ្លើយតបឱ្យបានទាន់ពេលវេលា ដើម្បីកាត់បន្ថយហានិភ័យដែលបណ្តាល មកពីគ្រោះមហន្តរាយ និងរាល់ជំងឺឆ្លងរាតត្បាតកាចសាហាវនានានៅតាម "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" រាជធានី-ខេត្ត ព្រមទាំងជូនជារង្វាន់ដល់ ភូមិ ឃុំ-សង្កាត់ដែលមានស្នាដៃ
- រាល់ផែនការ និងបទដ្ឋានគតិយុទ្ធផ្សេងៗ ឧបករណ៍ និងសូចនាករ ដែលបានរៀបចំរួចត្រូវដាក់ចូលទៅគណៈកម្មការចលនាប្រឡងប្រណាំងដើម្បីពិនិត្យ និងអនុមតិជាផ្លូវការ។

**ប្រការ៣.-**

ក្រុមការងារបច្ចេកទេស រៀបចំការអនុវត្តចលនាប្រឡងប្រណាំងគោលនយោបាយ "ភូមិ ឃុំ-សង្កាត់មានសុវត្ថិភាព" ត្រូវបំពេញភារកិច្ចផ្សេងៗទៀត តាមការណែនាំរបស់ប្រធានគណៈកម្មការ

សមាជិកក្រុមការងារត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**ប្រការ៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

នាយកខុទ្ទកាល័យក្រសួងសុខាភិបាល អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការក្រសួងសុខាភិបាល នាយកដ្ឋានការពារសុខភាព នាយកដ្ឋានពាក់ព័ន្ធ មជ្ឈមណ្ឌលជាតិ វិទ្យាស្ថានជាតិ មន្ទីរពេទ្យជាតិ អង្គភាពក្រោមឱវាទក្រសួងសុខាភិបាល អង្គការដៃគូ និងសាម៉ីខ្លួន ដូចមាននៅក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៧កើត ខែ ភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ២០២១

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ម៉ម_ប៊ុនហេង**